**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

EAC
**អាជ្ញាធរអគ្គិសនីកម្ពុជា**

លេខ ០៧៦.ផក.២៤ អអក

ថ្ងៃព្រហស្បតិ៍ ១៣រោច ខែជេស្ឋ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ៤ ខែកក្កដា ឆ្នាំ២០២៤

# សេចក្តីជូនដំណឹង
## ស្តីពី
## ការធ្វើស្វ័យប្រកាសពីការដំឡើង និងប្រើប្រាស់ប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យ

អាជ្ញាធរអគ្គិសនីកម្ពុជាមានកិត្តិយសសូមជម្រាបជូនឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី នាងកញ្ញា ជាអ្នកប្រើប្រាស់អគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជាមេត្តាជ្រាបថា កន្លងមក អាជ្ញាធរអគ្គិសនីកម្ពុជាបានចេញលិខិតលេខ ១៤៩.ផក.២៣.អអក ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២៣ ជូនដំណឹងដល់អ្នកប្រើប្រាស់អគ្គិសនីទាំងអស់ ដែលបានដំឡើង និងប្រើប្រាស់ប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យ ដោយពុំទាន់មានការអនុញ្ញាត ឱ្យធ្វើស្វ័យប្រកាសពីការដំឡើង និងប្រើប្រាស់ប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យរបស់ខ្លួន ទៅកាន់អ្នកផ្គត់ផ្គង់អគ្គិសនី ឬអគ្គិសនីកម្ពុជា ឱ្យបានមុនថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៤។ មកដល់ពេលនេះ អាជ្ញាធរអគ្គិសនីកម្ពុជាសង្កេតឃើញថា នៅមានអ្នកប្រើប្រាស់អគ្គិសនីមួយចំនួនដែលបានដំឡើង និងប្រើប្រាស់ប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យលើដំបូលដោយពុំមានការអនុញ្ញាត នៅពុំទាន់បានធ្វើស្វ័យប្រកាសអំពីការដំឡើង និងប្រើប្រាស់ប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យរបស់ខ្លួន នៅឡើយ។

ជាថ្មីម្តងទៀត អាជ្ញាធរអគ្គិសនីកម្ពុជាសូមអំពាវនាវជាថ្មីម្តងទៀតដល់អ្នកប្រើប្រាស់អគ្គិសនីទាំងអស់ ដែលបានដំឡើង និងប្រើប្រាស់ប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យលើដំបូល ដែលពុំមានការអនុញ្ញាត ឬពុំទាន់បានចុះកិច្ចសន្យាប្រើប្រាស់ថ្លៃថាមពលពន្លឺព្រះអាទិត្យលើដំបូលជាមួយអ្នកផ្គត់ផ្គង់ សូមអញ្ជើញមកដាក់ពាក្យស្វ័យប្រកាសពីការប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យរបស់ខ្លួន ដូចមានក្នុង QR កូដ ភ្ជាប់ជូន នៅទីស្នាក់ការរបស់អគ្គិសនីកម្ពុជា ឬទីស្នាក់ការរបស់អ្នកផ្គត់ផ្គត់អគ្គិសនីឯកជន ដែលឋិតនៅក្នុងតំបន់ដែលខ្លួនកំពុងប្រើប្រាស់អគ្គិសនី ឬទីស្នាក់ការរបស់អាជ្ញាធរអគ្គិសនីកម្ពុជាដោយផ្ទាល់ ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ រហូតដល់ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៤។ សូមបញ្ជាក់ជូនថា អ្នកប្រើប្រាស់អគ្គិសនីដែលបានដំឡើង និងប្រើប្រាស់ប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យលើដំបូល ពុំមានការអនុញ្ញាត ហើយបានធ្វើស្វ័យប្រកាសក្នុងរយៈពេលកំណត់ខាងលើ នឹងត្រូវចាត់ទុកថា ជាអ្នកប្រើប្រាស់មានការអនុញ្ញាត ដោយឡែក ចំពោះអ្នកប្រើប្រាស់

អគ្គិសនីដែលបានដំឡើង និងប្រើប្រាស់ប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យលើដំបូល ពុំមានការអនុញ្ញាត ហើយពុំបានធ្វើស្វ័យប្រកាសក្នុងរយៈពេលកំណត់ខាងលើ នឹងត្រូវចាត់ទុកថា ជាអ្នកប្រើប្រាស់មានពុំការអនុញ្ញាត ដែលនឹងត្រូវបង់ថ្លៃប៉ះប៉ូវខ្ពស់ជាងអ្នកប្រើប្រាស់មានការអនុញ្ញាត និង/ឬ ផ្អាកជាបណ្តោះអាសន្ននូវការផ្គត់ផ្គង់អគ្គិសនីពីប្រភពបណ្តាញជាតិ។

អាស្រ័យហេតុនេះ សូមឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី នាងកញ្ញា ជាអ្នកប្រើប្រាស់អគ្គិសនី មេត្តាជ្រាប និងអនុវត្តតាមការណែនាំខាងលើ ដោយអនុគ្រោះ។

សូមឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី នាងកញ្ញា ជាអ្នកប្រើប្រាស់អគ្គិសនី មេត្តាទទួលនូវការគោរព អំពីយើងខ្ញុំ។

**អាជ្ញាធរអគ្គិសនីកម្ពុជា**
**ប្រធាន**

**យឹម វិសិដ្ឋ**

**ចម្លងជូន**
-ក្រសួងរ៉ែ និងថាមពល
-មន្ទីររ៉ែ និងថាមពលរាជធានី-ខេត្ត
"ដើម្បីជូនជ្រាប"
-អគ្គិសនីកម្ពុជា
-អ្នកផ្គត់ផ្គង់អគ្គិសនីឯកជនពាក់ព័ន្ធ
"ដើម្បីចូលរួមអនុវត្ត"
-ឯកសារនិងកាលប្បវត្តិ

ទម្រង់ពាក្យស្វ័យប្រកាស
ព័ត៌មានបន្ថែម៖
០៩៦ ៧៦៨ ៨២៥៥
០៨៥ ៩៩៣ ៣៣៣

**អាជ្ញាធរអគ្គិសនីកម្ពុជា៖** អគារលេខ៧៦២ វិថីអយស្ម័យយានបស្ទិម (លេខ១១៣) ភូមិ១ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
ទូរស័ព្ទ : ០២៣ ២១៧ ៦៥៤ / ៩៨៧ ៨៩៨ ទូរសារ : ០២៣ ២១៤ ១៤៤, អ៊ីម៉ែល : admin@eac.gov.kh ; Website : www.eac.gov.kh